ACCESS 2
Sustainable quality services for all

Australian Aid

# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែក ការស្តារលទ្ធភាពពលកម្ម

exceed
equip, enable, empower

## សង្ខេបគម្រោង

អង្គការអ៊ិកស៊ីតដ៍វើលវ៉ាយដ៍ (Exceed Worldwide) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ មានមូលដ្ឋាននៅប្រទេសអង់គ្លេស ដែលបានកំពុងជួយផ្តល់សេវាស្តារលទ្ធភាពពលកម្មដល់ជនមានពិការភាព និងការបណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេសអវយវៈសិប្បនិម្មិត និងរណបនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង៣០ឆ្នាំ។ យោងតាមសេចក្តីសម្រេចលេខ៩០៧ ចុះថ្ងៃទី១៩ខែតុលាឆ្នាំ២០២២របស់រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្ទេរសេវាស្តារលទ្ធភាពពលកម្ម និងការបណ្តុះបណ្តាលពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទៅក្រសួងសុខាភិបាល ដោយផ្អែកទៅតាមបរិបទពិភពលោក និងស្តង់ដារអង្គការសុខភាពពិភពលោក ដែលសេវាស្តារលទ្ធភាពពលកម្មជាផ្នែកមួយរបស់សេវាសុខាភិបាល អង្គការអ៊ិកស៊ីតដ៍វើលវ៉ាយក៏មានឆន្ទៈក្នុងការផ្តល់ពង្រឹង និងបញ្ចូលសេវា ស្តារលទ្ធភាពពលកម្ម និងបណ្តុះបណ្តាលអ្នកជំនាញទៅក្នុងក្របខណ្ឌក្រសួងសុខាភិបាល។ គោលដៅសំខាន់នៃគម្រោង គឺការជួយពង្រឹងសេវាស្តារជាមួយក្រសួងសុខាភិបាល និងរួមចំណែកដល់ការធានាថា ជនមានពិការភាពអាចទទួលបានសេវា គ្រឿងជំនួយបន្លាស់ទីតាមតម្រូវការ។ តាមរយៈដំណើរការពង្រឹងសេវាស្តារលទ្ធភាពនេះ សេវានេះនឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួងសុខាភិបាល មានស្វ័យភាព មានប្រព័ន្ធ និងយន្តការគ្រប់គ្រងលំហូរហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។ តាមរយៈការគាំទ្រពីកម្មវិធីACCESS 2 អង្គការអ៊ិកស៊ីតដ៍វើលវ៉ាយដ៍នឹងបង្កើតសេវាថ្មីសម្រាប់ការផ្តល់សេវាស្តារលទ្ធភាពពលកម្មដោយបានចាប់យកគម្រូតាមសេវាឯកជនបន្ថែមទៅលើធនធានសាធារណដែលបានផ្តល់ឱ្យ តាមការផ្គត់ផ្គង់ធនធានឱ្យគ្នាទៅវិញទៅមក។

## លទ្ធផលរំពឹងទុករបស់គម្រោង

- និរន្តភាពសេវាស្តារលទ្ធភាពពលកម្មតាមម៉ូឌែលបង្កើតថ្មីសម្រាប់មន្ទីរពេទ្យថ្នាក់ជាតិនៅភ្នំពេញ។
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មដែលមានស្រាប់ចំនួនពីរត្រូវបានបញ្ចូលជាផ្នែកមួយរបស់សេវាមន្ទីរពេទ្យទាំងការគ្រប់គ្រង និងយន្តការផ្គត់ផ្គង់ហិរញ្ញវត្ថុ។

- សេវាស្តារលទ្ធភាពពលកម្មត្រូវបានពង្រឹងនៅក្នុងក្របខ័ណ្ឌក្រសួងសុខាភិបាល។
- ការបណ្តុះបណ្តាលអ្នកបច្ចេកទេសអវយវៈសិប្បនិម្មិតនិងរណប ត្រូវបានបញ្ចូលក្នុងកម្មវិធីអប់រំក្រសួងសុខាភិបាល ដោយមានការពង្រឹងប្រកបដោយនិរន្តរភាព។
- អ្នកបច្ចេកទេសអវយវៈសិប្បនិម្មិតនិងរណបត្រូវបានទទួលស្គាល់ជាអ្នកផ្តល់សេវាសុខភាពជាមួយនឹងការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការ។

**សកម្មភាពសំខាន់ៗ**

- ផ្នែកការស្តារលទ្ធភាពពលកម្ម មានបុគ្គលិកជំនាញត្រូវបានបង្កើតឡើងនៅក្នុងមន្ទីរពេទ្យថ្នាក់ជាតិចំនួនបួន និងមន្ទីរពេទ្យឯកជនចំនួនពីរនៅភ្នំពេញ ដូច្នេះសេវាកម្មស្តារត្រូវបានផ្តល់បានពេញលេញសម្រាប់ជនមានពិការភាព។
- រោងជាងផលិតថ្នាក់កណ្តាលត្រូវបានបង្កើតឡើងនៅក្រុងភ្នំពេញ ដើម្បីផ្គត់ផ្គង់ការផលិតឧបករណ៍គ្រឿងជំនួយស្តារសម្រាប់មន្ទីរពេទ្យទាំងប្រាំមួយ។
- បញ្ចូលសេវាស្តារលទ្ធភាពពលកម្មដែលមានស្រាប់នៅក្នុងខេត្តព្រះសីហនុ និងខេត្តក្រចេះទៅក្នុងសេវារបស់មន្ទីរពេទ្យ។
- អង្គការអ៊ិកស៊ីតដ៍រើលវ៉ាយដ៍ ដោយសហការជាមួយដៃគូរនានាក្នុងវិស័យស្តារ ចូលរួមក្នុងគណកម្មការពិគ្រោះយោបល់ដើម្បីពង្រឹងសេវាស្តារលទ្ធភាពពលកម្មសម្រាប់ក្រសួងសុខាភិបាល។
- អង្គការអ៊ិកស៊ីតដ៍រើលវ៉ាយដ៍ ដោយសហការជាមួយដៃគូរនានា ក្នុងការដឹកនាំដោយក្រសួងសុខាភិបាល ចូលរួមប្រឹក្សាយោបល់សម្រាប់ការបង្កើតកញ្ចប់ថវិកាគាំទ្រដល់សេវាស្តារតាមរយៈមូលនិធិសមធម៌ មូលនិធិរ៉ាប់រងសន្តិសុខសង្គម និងកញ្ចប់ថវិកាផ្នែកសង្គមផ្សេងទៀត ដើម្បីជួយនិរន្តរភាពដល់ផ្នែកសេវាស្តារលទ្ធភាពពលកម្ម ដោយការផ្តល់ជាធនធានដើម្បីទ្រទ្រង់សេវាទាំងនេះ។
- អង្គការអ៊ិកស៊ីតដ៍រើលវ៉ាយដ៍ដោយសហការជាមួយដៃគូរនានា ចូលរួមសហការជាមួយក្រសួងសុខាភិបាល និងក្រសួងមុខងារសាធារណៈក្នុងការធ្វើឱ្យមានការទទួលស្គាល់អ្នកជំនាញស្តារលទ្ធភាពពលម្មជាអាជីពផ្លូវការ។
- អង្គការអ៊ិកស៊ីតដ៍រើលវ៉ាយដ៍ ដោយសហការជាមួយដៃគូរនានាក្នុងការជួយធានាឱ្យមានអ្នកជំនាញស្តារគ្រប់គ្រាន់សម្រាប់សេវាស្តារ ដោយការគាំទ្រលើការបណ្តុះបណ្តាលផ្លូវការ។

**អ្នកទទួលផល**

**អ្នកទទួលផលដោយផ្ទាល់**

- ជនមានពិការភាពដែលបានប្រើប្រាស់ឧបករណ៍ជំនួយស្តារលទ្ធភាពពលកម្មជាយូរមកហើយ នៅតែអាចទទួលបានសេវាស្តារ ដូចជាជើងសិប្បនិម្មិត រណប រទេះ ឈើច្រត់ ។ល។

- អ្នកមានជម្ងឺមិនឆ្លងដូចជាទឹកនោមផ្អែម លើសឈាម បញ្ហាសរសៃឈាម នឹងអាចទទួលបានការអន្តរគមផ្នែកស្តារ ទាន់ពេលវេលា ដោយមានយន្តការបញ្ជូនកាន់តែប្រសើជាងមុន។
- កុមារមានបញ្ហាពិការភាពពីកំណើត ឬមានការបញ្ហាមុខងាររាងកាយដែលត្រូវការគ្រឿងជំនួយស្តារនឹងទទួលបានទាន់ពេលដើម្បីជួយទប់ស្កាត់ ការប៉ះពាល់និងកាត់បន្ថយកំហូចទ្រង់ទ្រាយ។

**អ្នកទទួលផលដោយប្រយោល**

- គ្រួសារអ្នកមានពិការភាពដែលអាចនាំឱ្យបាត់បង់សមត្ថភាពរកប្រាក់ចំណូល ដោយសមាជិកគ្រួសារមានពិការភាព។
- សហគមន៍អាចផ្លាស់ប្តូរផ្នត់គំនិតចំពោះជនមានពិការភាព ដោយមានការចូលរួមពីពួកគាត់ក្នុងការងារសង្គមនានាដែលនាំឱ្យមានការកាត់បន្ថយការរើសអើង។
- ស្ត្រីឬកុមារដែលត្រូវបានទទួលបន្ទុកថែទាំសមាជិកគ្រួសារវ័យចំណាស់ ដែលមានពិការភាព ដោយការទទួលបានសេវាស្តារលទ្ធភាពពលកម្មសមស្រប អាចជួយកាត់បន្ថយបន្ទុកគ្រួសារ។
- អ្នកជំនាញថ្មីដែលទើបរៀនចប់ (អាចជាភាគច្រើនជាជនមានពិការភាព) អាចចូលរួមកម្លាំងការងារក្នុងវិស័យស្តា។

**តំបន់គោលដៅ**

ទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និង ខេត្តក្រចេះ

**ដៃគូអនុវត្តគម្រោង**

ក្រសួងសុខាភិបាល

មន្ទីរពេទ្យកុមារជាតិមន្ទីរពេទ្យខេត្តព្រះសីហនុ មន្ទីរពេទ្យខេត្តក្រចេះ បន្តពិភាក្សាជាមួយមន្ទីរពេទ្យជាតិបីទៀត និងមន្ទីរពេទ្យឯកជនពីរទៀតនៅភ្នំពេញ

**រយៈពេលអនុវត្តគម្រោង**

ខែមករា ២០២៤ ដល់ ខែមិថុនា ២០២៨

**ព័ត៌មានទំនាក់ទំនង**

| | |
|---|---|
| អង្គការ Exceed<br>លោកស្រី ខេង ស៊ីសារី<br>នាយិកាប្រចាំប្រទេសកម្ពុជា<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៤៩២ ៣៦១<br>អ៊ីម៉ែល៖ sisary@exceed-worldwide.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ Vivath.Chou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយ និរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤